ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :១០៣.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាត

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់ពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាតសម្រាប់ប្រើដើម្បីបំពេញការងារចុះអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យប្រេងកាត នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ឯកសណ្ឋាន

**មាត្រា២ .-**

ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចប្រេងកាត មានដូចខាងក្រោម៖

- សម្លៀកបំពាក់
- មួក និង
- សញ្ញាសក្តិ។

**មាត្រា៣ .-**

សម្លៀកបំពាក់របស់មន្ត្រីអធិការកិច្ចប្រេងកាតត្រូវបានកំណត់យកប្រភេទសាច់ក្រណាត់និងពណ៌កាគី លើកលែងតែនៅក្នុងទីតាំងដែលត្រូវទាមទារការការពារពិសេសដែលនឹងត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

## ផ្នែកទី១

## សម្លៀកបំពាក់

**មាត្រា៤ .-**

ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចប្រេងកាតត្រូវបានកំណត់ដូចខាងក្រោម៖

១. ចំពោះបុរស

- អាវដៃខ្លី កបើក ថ្នេរឌុប ប៉ូលស្មាសងខាងជីបចង្កេះ សម្រុងជើងអាវត្រង់ស្មើ ផែកពីក្រោយសងខាងតាមបណ្តោយខ្លួន ហើយមានហោប៉ៅចំនួន៤(បួន) ហោប៉ៅខាងលើដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរបត់ប៉ះផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ និងមានឡេវចំនួន៦(ប្រាំមួយ)គ្រាប់
- អាវដៃវែង កបើក ថ្នេរឌុប ប៉ូលស្មាសងខាង ជីបភ្លីខាងមុខ២(ពីរ) ពីក្រោមរហូតដល់លើសម្រុងជើងអាវត្រង់ស្មើ ផែកពីក្រោយសងខាងតាមបណ្តោយខ្លួន ហើយមានហោប៉ៅចំនួន៤(បួន) ហោប៉ៅខាងលើដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរគ្មានផ្នត់កណ្តាលមានគម្របរាងចតុកោណកែង ផ្នែកខាងក្រោយមានជីបភ្លីចំនួន២(ពីរ) និងមានឡេវចំនួន៦(ប្រាំមួយ)គ្រាប់

- ខោជើងវែងមានពណ៌ដូចអាវ ដេរថ្នេរបង្កប់ ចង្កេះត ជីបភ្លីខាងមុខ២(ពីរ) មានហោប៉ៅចំនួន ៣(បី)ហោប៉ៅខាងក្រោយ១(មួយ)ដេរថ្នេរបង្កប់មានគម្របរាងស្លឹកពោធិ៍ចោះរន្ធដាក់ឡេវ ចំនួន១(មួយ)គ្រាប់ និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់តាមថ្នេរ
- ខ្សែក្រវាត់ស្បែកពណ៌ខ្មៅ
- ស្បែកជើងឃ្លុបចងខ្សែ កខ្លី ស្បែកពណ៌ខ្មៅនិងមានស្រោមជើងពណ៌ខ្មៅ និង
- ស្បែកជើងឃ្លុប កវែង ពណ៌ខ្មៅនិងមានស្រោមជើងពណ៌ខ្មៅ។

២. **ចំពោះនារី**

- អាវម៉ូតដូចបុរស ប៉ុន្តែកអាវមានរាងកអាវរបស់ស្ត្រី
- ខោម៉ូតដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ
- ខ្សែក្រវាត់ស្បែកពណ៌ខ្មៅ
- ស្បែកជើងឃ្លុបចងខ្សែ កខ្លី ស្បែកពណ៌ខ្មៅនិងមានស្រោមជើងពណ៌ខ្មៅ និង
- ស្បែកជើងឃ្លុប កវែង ពណ៌ខ្មៅ និងមានស្រោមជើងពណ៌ខ្មៅ។

គំរូសម្លៀកបំពាក់របស់មន្ត្រីអធិការកិច្ចប្រេងកាតត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

គំរូខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងរបស់មន្ត្រីអធិការកិច្ចប្រេងកាត សម្រាប់បុរសត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

គំរូខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងរបស់មន្ត្រីអធិការកិច្ចប្រេងកាត សម្រាប់នារីត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

## ផ្នែកទី២
## មួក

**មាត្រា៥ .-**

មួករបស់មន្ត្រីអធិការកិច្ចប្រេងកាត ជាមួកកាស្កែតធ្វើពីសាច់ក្រណាត់និងពណ៌ដូចសម្លៀកបំពាក់ ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាសទំហំកម្ពស់៧,៨(ប្រាំពីរក្បៀសប្រាំបី)សង់ទីម៉ែត្រ ទទឹង៦,៨(ប្រាំមួយក្បៀសប្រាំបី)សង់ទីម៉ែត្រ។ នៅខាងក្រោមព្រះរាជសង្ហារនេះ មានកណ្ដាប់វណ្ណប៉ាន ពណ៌ខ្មៅនិងមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសចំកណ្ដាលខាងមុខដល់ជើងមួកឬគ្មានតាមថ្នាក់នីមួយៗ។ នៅផ្នែកខាងក្រោមកណ្ដាប់វណ្ណប៉ានពណ៌ខ្មៅមានខ្សែឆ្វាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែឆ្វាក់វេញ នេះមានភ្ជាប់ឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២(ពីរ)គ្រាប់។ ក្បាំងមួកមានពណ៌ខ្មៅ ផ្នែកខាងមុខនៃ ក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្ដាលនិងអមដោយក្បាច់សន្លឹកភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របី ដល់ជើងមួកឬពាក់កណ្ដាលជើងមួកតាមថ្នាក់នីមួយៗ។ គែមរបស់ក្បាំងមួកមានវណ្ណទំហំ០,៥(សូន្យ ក្បៀសប្រាំ)សង់ទីម៉ែត្រ ពណ៌មាសព័ទ្ធដល់ជើងមួក ឬគ្មានតាមថ្នាក់នីមួយៗ។

មួកកាស្កែតនេះត្រូវបានកំណត់ជា៤(បួន)ថ្នាក់ដូចខាងក្រោម៖

១. **ថ្នាក់អគ្គនាយក** : ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាស នៅលើកណ្ដាប់វណ្ណប៉ានពណ៌ខ្មៅមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសចំកណ្ដាលខាងមុខដល់ជើងមួក។

នៅផ្នែកក្រោមប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសនេះមានខ្សែឆ្វាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែឆ្វាក់វេញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាលនិងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាង៦(ប្រាំមួយ)ទងពណ៌មាស ទម្រង់ស្នែងក្របីចុងសងខាងដល់ជើងមួក និងគែមរបស់ក្បាំងមួកមានវណ្ឌទំហំ ០,៥ (សូន្យក្បៀសប្រាំ)សង់ទីម៉ែត្រពណ៌មាសព័ទ្ធដល់ជើងមួក។

២. **ថ្នាក់អគ្គនាយករងនិងថ្នាក់ប្រធាននាយកដ្ឋាន** : ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាស នៅលើកណ្តាប់វណ្ឌប៉ានពណ៌ខ្មៅមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសចំកណ្តាលខាងមុខដល់ជើងមួក។ នៅផ្នែកក្រោមប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសនេះមានខ្សែឆ្វាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែឆ្វាក់វេញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាលនិងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាង៦(ប្រាំមួយ)ទងពណ៌មាស ទម្រង់ស្នែងក្របីចុងសងខាងដល់ជើងមួក។

៣. **ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានការិយាល័យ** : ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាស នៅលើកណ្តាប់វណ្ឌប៉ានពណ៌ខ្មៅមិនមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសទេ មានខ្សែឆ្វាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែឆ្វាក់វេញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាង៤(បួន)ទងពណ៌មាសទម្រង់ស្នែងក្របី។

៤. **ថ្នាក់អនុប្រធានការិយាល័យនិងមន្ត្រី** : ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាស នៅលើកណ្តាប់វណ្ឌប៉ានពណ៌ខ្មៅមិនមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសទេ មានខ្សែឆ្វាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែឆ្វាក់វេញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាលនិងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាង២(ពីរ)ទងពណ៌មាសទម្រង់ស្នែងក្របី។

គំរូមួករបស់មន្ត្រីអធិការកិច្ចប្រេងកាតត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ។

## ផ្នែកទី៣
## សញ្ញាសក្តិ

**មាត្រា៦ .-**

សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចប្រេងកាតសម្រាប់ពាក់លើស្មាអាវសងខាង ត្រូវបានកំណត់ជា៤(បួន) ថ្នាក់ដូចខាងក្រោម៖

១. **ថ្នាក់អគ្គនាយក** : សញ្ញាសក្តិមានផ្ទៃពណ៌ខ្មៅព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌មាសពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះរាជសង្ហារពណ៌មាសមួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញានិមិត្តរូបរបស់ក្រសួងរ៉ែនិងថាមពលពណ៌មាស។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌មាសប្រាំខ្សែនិងមានក្បាច់ផ្កាចន្ទន៍និងក្បាច់ភ្ញីទេសពណ៌មាស ព្រមទាំងមានប៉ាក់អក្សរកាត់ "**អ.ក.ប.ក.**"។

២. **ថ្នាក់អគ្គនាយករងនិងថ្នាក់ប្រធាននាយកដ្ឋាន** : សញ្ញាសក្តិមានផ្ទៃពណ៌ខ្មៅព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌មាសពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះរាជសង្ហារពណ៌មាសមួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញានិមិត្តរូបរបស់ក្រសួងរ៉ែនិងថាមពលពណ៌មាស។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌មាសបីខ្សែនិងមានក្បាច់ផ្កាចន្ទន៍និងក្បាច់ភ្ញីទេសពណ៌មាស ព្រមទាំងមានប៉ាក់អក្សរកាត់ "**អ.ភ.ប.ភ.**"។

៣. **ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានការិយាល័យ** : សញ្ញាសក្តិមានផ្ទៃពណ៌ខ្មៅព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌មាសពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះរាជសង្ហារពណ៌មាសមួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញានិមិត្តរូបរបស់ក្រសួងរ៉ែនិងថាមពលពណ៌មាស។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌មាសមួយខ្សែនិងមានក្បាច់ផ្កាចន្ទន៍និងក្បាច់ភ្ញីទេសពណ៌មាស ព្រមទាំងមានប៉ាក់អក្សរកាត់ "**អ.ភ.ប.ភ.**"។

៤. **ថ្នាក់អនុប្រធានការិយាល័យនិងមន្ត្រី** : សញ្ញាសក្តិមានផ្ទៃពណ៌ខ្មៅព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌មាសពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះរាជសង្ហារពណ៌មាសមួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញានិមិត្តរូបរបស់ក្រសួងរ៉ែនិងថាមពលពណ៌មាស។ ផ្នែកខាងក្រោមមានក្បាច់ផ្កាចន្ទន៍និងក្បាច់ភ្ញីទេស ពណ៌មាស ព្រមទាំងមានប៉ាក់អក្សរកាត់ "**អ.ភ.ប.ភ.**"។

គំរូសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចប្រេងកាតត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## សញ្ញាសម្គាល់និងបណ្ណសម្គាល់ខ្លួន
### ផ្នែកទី១
### សញ្ញាសម្គាល់

**មាត្រា៧ .-**

សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាតត្រូវបានកំណត់ដូចខាងក្រោម៖

១. សញ្ញាពាក់នៅលើដើមដៃអាវខាងស្តាំ ជាសញ្ញានិមិត្តរូបរបស់ក្រសួងរ៉ែនិងថាមពលធ្វើអំពីសាច់ក្រណាត់ក្រាស់ រាងជារង្វង់មានអង្កត់ផ្ចិតប្រវែង៨(ប្រាំបី)សង់ទីម៉ែត្រ។

២. សញ្ញាពាក់នៅលើដើមដៃអាវខាងឆ្វេង ជាសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាត ធ្វើអំពីសាច់ក្រណាត់ក្រាស់រាងរូបតំណក់ប្រេងកាតមានពណ៌ទឹកមាស និងមានអង្កត់ផ្ចិតប្រវែង៨(ប្រាំបី)សង់ទីម៉ែត្រ

៣. សញ្ញាសម្រាប់ពាក់ជាប់ចុងកអាវ សម្គាល់សញ្ញារបស់មន្ត្រីអធិការកិច្ចប្រេងកាត មានរូបតំណក់ប្រេងកាតធ្វើពីលោហធាតុមានពណ៌ទឹកមាស និងមានអង្កត់ផ្ចិតប្រវែង៣(បី)សង់ទីម៉ែត្រ។

៤. ស្លាកសម្គាល់ឈ្មោះមន្ត្រី សម្រាប់ពាក់នៅពីលើហោប៉ៅអាវខាងស្តាំមានរាងចតុកោណកែងដែលមានបណ្តោយប្រវែង៩,៥(ប្រាំបួនក្បៀសប្រាំ)សង់ទីម៉ែត្រ ទទឹង២(ពីរ)សង់ទីម៉ែត្រដែលសរសេរអក្សរពណ៌ទឹកមាសនិងពាសដោយជ័ររឹងថ្លាមានផ្ទៃពណ៌ខ្មៅ និងមានខ្សែបន្ទាត់ស្តើងពណ៌មាសព័ទ្ធជុំវិញដែលមានទំហំ០,១៥(សូន្យក្បៀសដប់ប្រាំ)សង់ទីម៉ែត្រ។ ប៉ែកខាង

ស្តាំដៃនៃស្លាកឈ្មោះមានសញ្ញានិមិត្តរូបរបស់ក្រសួងរ៉ែនិងថាមពល និងប៉ែកខាងឆ្វេងមានសរសេរគោត្តនាមនិងនាមជាអក្សរខ្មែរ អក្សរឡាតាំង និងមានឈ្មោះអង្គភាពរបស់មន្ត្រីអធិការកិច្ចប្រេងកាត។

៥- សញ្ញាសម្គាល់នគរបាលយុត្តិធម៌ក្រសួងរ៉ែនិងថាមពលមានរូបសញ្ញានិមិត្តរូបរបស់ក្រសួងរ៉ែនិងថាមពល ធ្វើពីលោហធាតុរាងមូលប៉ោង ទំហំអង្កត់ផ្ចិត៥(ប្រាំ)សង់ទីម៉ែត្រ ពណ៌មាសផុសឡើងភ្ជាប់លើបន្ទះស្បែកពណ៌ត្នោតចាស់សម្រាប់ព្យួរនៅហោប៉ៅអាវលើខាងស្តាំ។ នៅផ្ទៃរង្វង់មានសរសេរអក្សរខ្មែរពណ៌មាស "នគរបាលយុត្តិធម៌" នៅចុងអង្កត់ផ្ចិតនៃពាក្យនេះមានលម្អដោយផ្កាចន្ទន៍។

គំរូសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាតត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យនេះ។

## ផ្នែកទី២
## បណ្ណសម្គាល់ខ្លួន

**មាត្រា៨ .-**

មន្ត្រីអធិការកិច្ចប្រេងកាតត្រូវមានបណ្ណសម្គាល់ខ្លួនដើម្បីបញ្ជាក់អត្តសញ្ញាណក្នុងពេលបំពេញភារកិច្ចដែលចេញដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

បណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចប្រេងកាតត្រូវមានអត្តលេខ ឈ្មោះ បិទរូបថត ចុះហត្ថលេខានិងបោះត្រាជាផ្លូវការរបស់ក្រសួងរ៉ែនិងថាមពល។

**មាត្រា៩ .-**

ក្នុងពេលបំពេញបេសកកម្មមន្ត្រីអធិការកិច្ចប្រេងកាតត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់និងមានបណ្ណសម្គាល់ខ្លួន ព្រមទាំងលិខិតបញ្ជាបេសកកម្ម។

**មាត្រា១០ .-**

ឯកសណ្ឋាននិងសញ្ញាសម្គាល់ដូចបានកំណត់ក្នុងអនុក្រឹត្យនេះត្រូវបានផ្តល់ជូនមន្ត្រីអធិការកិច្ចប្រេងកាតក្នុងម្នាក់ៗចំនួន២(ពីរ)សម្រាប់ ដើម្បីប្រើប្រាស់ក្នុងរយៈពេល១(មួយ)ឆ្នាំ តាមទំហំនៃថវិកាជាតិប្រចាំឆ្នាំដែលបានវិភាជជូន។

គំរូឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាតមានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី៧នៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## ទោសប្បញ្ញត្តិ

**មាត្រា១១ .-**

ជនណាក្លែងបន្លំដោយស្លៀកពាក់ឯកសណ្ឋាននិងសញ្ញាសម្គាល់មន្ត្រីអធិការកិច្ចប្រេងកាតរបស់ក្រសួងរ៉ែនិងថាមពល ដូចមានកំណត់ក្នុងអនុក្រឹត្យនេះត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០២០

ស្ដីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាត

### ១- គំរូសម្លៀកបំពាក់របស់មន្ត្រីអធិការកិច្ចប្រេងកាត

#### ១.១- រូបគំរូសម្លៀកបំពាក់បុរសអាវដៃខ្លី អាវដៃវែង និងខោ

អាវដៃខ្លី



អាវដៃវែង



## ខោ



## ១.២_ គំរូសម្លៀកបំពាក់នារីអាវដៃខ្លី អាវដៃវែង និងខោ

### អាវដៃខ្លី



## អាវដៃវែង



## ខោ



## ឧបសម្ព័ន្ធទី២

## នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០២០

## ស្តីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាត

### ២_ គំរូខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងរបស់មន្ត្រីអធិការកិច្ចប្រេងកាតសម្រាប់បុរស

#### ២.១_ ខ្សែក្រវាត់ស្បែកពណ៌ខ្មៅ



#### ២.២_ ស្បែកជើងឃ្លុបចងខ្សែ កខ្លី ស្បែកពណ៌ខ្មៅ



#### ២.៣_ ស្បែកជើងឃ្លុបកវែងពណ៌ខ្មៅ



#### ២.៤_ ស្រោមជើងពណ៌ខ្មៅ



**ឧបសម្ព័ន្ធទី៣**

**នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០២០**

**ស្ដីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាត**

**៣_ គំរូខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងរបស់មន្ត្រីអធិការកិច្ចប្រេងកាតសម្រាប់នារី**

**៣.១_ គំរូខ្សែក្រវាត់ស្បែកពណ៌ខ្មៅ**



**៣.២_ ស្បែកជើងឃ្លុបចងខ្សែ កខ្លី ស្បែកពណ៌ខ្មៅ**



**៣.៣_ ស្បែកជើងឃ្លុបកវែងពណ៌ខ្មៅ**



**៣.៤_ ស្រោមជើងពណ៌ខ្មៅ**



ឧបសម្ព័ន្ធទី៤

នៃអនុក្រឹត្យលេខ.១០៣ អនក្រ.បក.....ចុះថ្ងៃទី.១៦....ខែ.កក្កដា....ឆ្នាំ.២០២០......

ស្តីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាត

៤- គំរូមួករបស់មន្ត្រីអធិការកិច្ចប្រេងកាត

៤.១- ថ្នាក់អគ្គនាយក



៤.២- ថ្នាក់អគ្គនាយករងនិងថ្នាក់ប្រធាននាយកដ្ឋាន



## ៤.៣_ ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានការិយាល័យ



## ៤.៤_ ថ្នាក់អនុប្រធានការិយាល័យនិងមន្ត្រី



# ឧបសម្ព័ន្ធទី៥

នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០២០

## ស្តីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាត

### ៥_ គំរូសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចប្រេងកាត

#### ៥.១_ ថ្នាក់អគ្គនាយក




#### ៥.២_ ថ្នាក់អគ្គនាយករងនិងថ្នាក់ប្រធាននាយកដ្ឋាន



## ៥.៣_ ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានការិយាល័យ




## ៥.៤_ ថ្នាក់អនុប្រធានការិយាល័យនិងមន្ត្រី



**ឧបសម្ព័ន្ធទី៦**

**នៃអនុក្រឹត្យលេខ** ១០៣ អនក្រ.បក **ចុះថ្ងៃទី** ១៦ **ខែ** កក្កដា **ឆ្នាំ** ២០២០

**ស្តីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាត**

**៦- គំរូសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាត**

**៦.១- សញ្ញាពាក់នៅលើដើមដៃអាវខាងស្តាំ**




**៦.២- សញ្ញាពាក់នៅលើដើមដៃអាវខាងឆ្វេង**



**៦.៣- សញ្ញាសម្រាប់ពាក់ជាប់ចុងកអាវ**



**៦.៤- ស្លាកសម្គាល់ឈ្មោះមន្ត្រី**



## ៦.៥_ សញ្ញាសម្គាល់នគរបាលយុត្តិធម៌

**ឧបសម្ព័ន្ធទី៧**

**នៃអនុក្រឹត្យលេខ** ១០៣ អនក្រ.បក **ចុះថ្ងៃទី** ១៦ **ខែ**កក្កដា **ឆ្នាំ**២០២០

**ស្ដីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាត**

**៧_ គំរូឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាត**

